# អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា

**Kampuchea Action to Promote Education (KAPE)**

## សេចក្តីជូនដំណឹងស្តីពី

## ការអញ្ជើញចូលរួមដេញថ្លៃសម្ភារព័ត៌មានវិទ្យាសម្រាប់គម្រោង

## ( ICT Materials of DViTSA-LED Project ) នៃអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា

## ក្រោមជំនួយថវិការបស់អង្គការ Liechtenstein Development Service ( LED )

អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការ ខេប) សូមជម្រាបជូនដំណឹងដល់ក្រុមហ៊ុន ឬអាជីវករ ផ្គត់ផ្គង់សម្ភារព័ត៌មានវិទ្យាក្នុងស្រុកទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា៖ គម្រោង DViTSA-LED Project នៃអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា នឹងដាក់ឱ្យចូលរួមដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសក្រុមហ៊ុន ឬអាជីវករ ទទួលផ្គត់ផ្គង់សម្ភារព័ត៌មានវិទ្យា មានដូចតទៅ៖ (1. Mac Mini M2 Chip ចំនួន៖ 18 Sets), (2. Logitech Pebble M350s Wireless & Bluetooth Mouse ចំនួន៖ 18 units), (3. K8 Pro Alum RGB Hot-Swap ចំនួន៖ 18 Sets), (4. MSI MODERN MD2412P ចំនួន៖ 36Sets) ។

ក្រុមហ៊ុន ឬអាជីវករ ទាំងអស់ដែលមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់ ក្នុងករណីពិនិត្យឃើញថាក្រុមហ៊ុន ឬអាជីវករ ដែលបានចូលរួមធ្វើការដេញថ្លៃ ជាក្រុមហ៊ុនមានសម្ព័ន្ធភាពជាមួយ ឬប្រភពតែមួយ នឹងត្រូវបដិសេធដោយស្វ័យប្រវត្តិ។

ក្រុមហ៊ុន ឬអាជីវករ ដែលមានចំណាប់អារម្មណ៍ សូមធ្វើការទាក់ទងមកអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ដើម្បីសាកសួរព័ត៌មានអំពីការចូលរួមដេញថ្លៃ និងការរៀបចំឯកសារភ្ជាប់ក្នុងការបញ្ជាក់លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃ និងឯកសារសម្រង់តម្លៃ រួមទាំងពាក្យសុំចូលរួមដេញថ្លៃ ចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤ រហូតដល់ **ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៤ វេលាម៉ោង ៥:០០នាទីល្ងាច ជាកំហិត។**

**អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា នឹងធ្វើការប្រជុំបើកកញ្ចប់ដេញថ្លៃ ដែលនឹងប្រព្រឹត្តិទៅ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៤ វេលាម៉ោង ០៩:០០នាទី ព្រឹក នៅបន្ទប់ប្រជុំការិយាល័យរង សាលារៀនជំនាន់ថ្មី វិទ្យាល័យ ព្រះស៊ីសុវត្ថិ រាជធានីភ្នំពេញ ។**

<u>បញ្ជាក់</u>៖

- ប្រសិនបើអ្នកដេញថ្លៃណាម្នាក់ដែលមិនបានចូលរួមប្រជុំបើកកញ្ចប់ឯកសារដេញថ្លៃទាន់ពេលវេលា ឬក៏អវត្តមានក្នុង (រយៈពេល ១៥នាទី ) ឯកសារដាក់ដេញថ្លៃនោះមិនអនុញ្ញាតដាក់បញ្ចូលក្នុងការបើកឡើយ។
- រាល់ឯកសារសម្រង់តម្លៃ និងពាក្យសុំចូលរួមការដេញថ្លៃទាំងអស់ ត្រូវប្រេកក្នុងស្រោមបិទជិត ដោយមានចុះហត្ថលេខា និងបោះត្រារបស់ក្រុមហ៊ុន ឬអាជីវករ នៅលើស្រោមសំបុត្រ រួចបញ្ជូនមកការិយាល័យរង សាលារៀនជំនាន់ថ្មី នៃអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការ ខេប) ដែលមានអាសយដ្ឋានស្ថិតនៅក្នុងបរិវេណវិទ្យាល័យ ព្រះស៊ីសុវត្ថិ រាជធានីភ្នំពេញ។ រាល់ឯកសារសម្រង់តម្លៃ និងពាក្យសុំចូលរួមការដេញថ្លៃទាំងអស់ ត្រូវបញ្ចូលពន្ធអាករលើតម្លៃបន្ថែម ១០% ហើយមិនអនុញ្ញាតឱ្យដាក់មកតាមរយៈសារអេឡិចត្រូនិច (អ៊ីមែល) ទេ។
- រាល់ឯកសារសម្រង់តម្លៃ និងពាក្យសុំចូលរួមការដេញថ្លៃទាំងអស់ ដែលមិនបានដាក់ជូនមកការិយាល័យរងរបស់អង្គការ ខេប ទាន់ពេលវេលាទេ ត្រូវចាត់ទុកជាអាសាបង់។
- ចំពោះអ្នកចូលរួមប្រជុំការបើកបញ្ចប់ឯកសារដេញថ្លៃទាំងអស់ដែលជាអ្នកមកតំណាងក្រុមហ៊ុន ឬអាជីវករ ត្រូវមានលិខិតផ្ទេរសិទ្ធិ ដែលមានចុះហត្ថលេខាត្រឹមត្រូវពីប្រធានក្រុមហ៊ុន ឬម្ចាស់អាជីវកម្ម។

**ព័ត៌មានផ្សេងៗសូមទំនាក់ទំនង៖**


ការិយាល័យកណ្តាលអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការ ខេប )

អាស័យដ្ឋាន ៖ ក្នុងបរិវេណសាលាគរុកោសល្យ និងវិក្រឹតការ ខេត្ត កំពង់ចាម

ការិយាល័យរង អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការ ខេប ) សាលារៀនជំនាន់ថ្មី

អាស័យដ្ឋាន ៖ ក្នុងបរិវេណវិទ្យាល័យ ព្រះស៊ីសុវត្ថិ រាជធានី ភ្នំពេញ

ឈ្មោះ ៖ ឈួន សារ៉ាន ជាប្រធានរដ្ឋបាល និងធនធានមនុស្ស

ទូរសព្ទ ៖ ០១២ ៧៥២ ៥៥៣, ០៩៦ ៤៦៤ ៧៧៧៧, ០៩៧ ៦៩៨ ៨៤៨៤

អ៊ីមែល ៖ saran@kapekh.org

ចម្លងជូន ៖ vanna@kapekh.org, sambath@kapekh.org, ladet@kapekh.org, sophanak@kapekh.org, phirun@kapekh.org, dara.chhuon@kapekh.org,


ថ្ងៃពុធ ១០រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

កំពង់ចាម, ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤

**នាយកប្រតិបត្តិ**

KAMPUCHEA ACTION TO PROMOTE EDUCATION ORG

**សៅ វណ្ណា**